ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការកំណត់រយៈពេលបំពេញការងារប្រចាំសប្តាហ៍**

**របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា**

* * * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១ :** មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារចំនួន ៥ថ្ងៃ ក្នុងមួយសប្ដាហ៍ និងត្រូវបានអនុញ្ញាតអោយឈប់សំរាកការងារចំនួន ២ ថ្ងៃ ក្នុងមួយសប្ដាហ៍ គឺថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ ។

**មាត្រា ២:** មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារអោយបានទៀងទាត់ តាមរយៈពេលដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះធ្វើការក្នុងមួយថ្ងៃចំនួន ៨ ម៉ោងគឺ ៖

- ព្រឹកពី ម៉ោង ៧ និង ០០នាទី ដល់ម៉ោង ១១ និង ៣០នាទី
- ល្ងាចពីម៉ោង ១៤ និង ០០នាទី ដល់ម៉ោង ១៧ និង ៣០នាទី ។

**មាត្រា ៣:** រយៈពេលបំរើការងារប្រចាំសប្ដាហ៍របស់សាស្ត្រាចារ្យ គ្រូបង្រៀន បុគ្គលិកសិក្សាតាមគ្រឹះស្ថានសិក្សានានា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

**មាត្រា ៤:** ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រី រាជការស៊ីវិលប្រចាំឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ សារាចរ និងលិខិតបទដ្ឋានផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល និង អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

**នាយករដ្ឋមន្ត្រី** **នាយករដ្ឋមន្ត្រី**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

**<u>កន្លែងទទួល</u>** ÷

-ខុទ្ទកាល័យ

-អគ្គនាយកដ្ឋានព្រះបរមរាជវាំង

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៦
- កាលប្បវត្តិ-ឯកសារ